**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ពិធីសម្ពោធសាខាបេឡាជាតិសន្តិសុខសង្គម និងមជ្ឈមណ្ឌលការងារ នៅផ្សារទំនើប អ៊ីអន ម៉ល សែនសុខ ស៊ីធី និងពិព័រណ៍ការងារ និងមគ្គុទេសក៍អាជីព

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន សិស្ស និស្សិត កម្មករនិយោជិត និយោជក និងអ្នកសារព័ត៌មាន ជ្រាបថា ក្រសួងនឹងរៀបចំពិព័រណ៍ការងារ និងមគ្គុទេសក៍អាជីព រយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៤ ដោយមានកិច្ចសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.) រាជធានីភ្នំពេញ សមាគមសហព័ន្ធសិស្ស និស្សិតអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងមានការចូលរួមគាំទ្រដោយក្រុមហ៊ុន អ៊ីអន ម៉ល (ខេមបូឌា) ខូអិលធីឌី និងក្រុមហ៊ុនធំៗចំនួន ២០ នឹងផ្តល់ឱកាសការងារជាង ៥ ០០០កន្លែង ដែលយុវជន សិស្ស និស្សិត អ្នកស្វែងរកការងារ អាចមកដាក់ពាក្យ និងសម្ភាសន៍ដោយផ្ទាល់ផងដែរ។ ពិព័រណ៍ការងារនេះ នឹងមានការតាំងបង្ហាញអំពីព័ត៌មានតម្រូវការជ្រើសរើសកម្លាំងពលកម្ម ឱកាសអាហារូបករណ៍ និងកម្មសិក្សាការងារ ពីសហគ្រាស ក្រុមហ៊ុនដែលជាដៃគូសហការ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងមានវេទិកាចែករំលែកចំណេះដឹងសម្រាប់ត្រៀមខ្លួនចូលទីផ្សារការងារ។ លើសពីនេះ សាធារណជននឹងមានឱកាសភ្លក់កាហ្វេដែលមានរសជាតិឈ្ងុយឆ្ងាញ់ពី Robot Coffee ដែលជាស្នាដៃរបស់និស្សិត TVET ហើយបងប្អូនក៏អាចចូលទស្សនាការប្រគុំតន្ត្រីដោយសេរីនាពេលល្ងាច និងមានឱកាសឈ្នះបានរង្វាន់ជាច្រើន។

ជាមួយគ្នានេះ ក្រសួងនឹងបើកសម្ពោធសាខាបេឡាជាតិសន្តិសុខសង្គម និងមជ្ឈមណ្ឌលការងារ នៅផ្សារទំនើប អ៊ីអន ម៉ល សែនសុខ ស៊ីធី (AEON MALL Sen Sok City) ជាន់ទី២ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៤ ដែលបង្កភាពងាយស្រួលដល់សមាជិក ប.ស.ស. និងសាធារណជនទូទៅ មកចុះឈ្មោះធ្វើប័ណ្ណ ប.ស.ស. និងដាក់ឯកសារស្នើសុំទូទាត់សំណង ប.ស.ស. បានផងដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈប្រព័ន្ធ Hotline លេខ "១២៨៦" ឬ "១២៩៧" ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន សិស្ស និស្សិត កម្មករនិយោជិត និយោជក និងអ្នកសារព័ត៌មាន ជ្រាបជាព័ត៌មាន និងចូលរួមឱ្យបានច្រើនកុះករ។

ថ្ងៃអង្គារ ៩កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤